# ការចិញ្ចឹមមាន់បានផ្លាស់ប្តូរជីវភាពរស់នៅរបស់កសិករ

ការចិញ្ចឹមសត្វ ដូចជា គោក្របី និងមាន់ទា បានធ្វើឲ្យចំណូល និងជីវភាពរស់នៅរបស់ពលរដ្ឋនៅក្នុងភូមិ ដា ខេត្តក្រចេះ មានភាពល្អប្រសើរជាងមុន។



*លោក ចំណាក់ កំពុងថែទាំមាន់របស់គាត់*

**លោក ចំណាក់ និងភរិយា បានចាប់ផ្តើមការចិញ្ចឹមមេមាន់២៨ក្បាល និងមាន់ឈ្មោល៤ក្បាល ហើយឥឡូវនេះ ពួកគាត់មានមាន់កើនឡើងលើសទ្វេដង។ ចាប់តាំងពីចាប់ផ្តើមការចិញ្ចឹមមាន់ពីខែកញ្ញា ឆ្នាំ២០១៦មក កូនមាន់ចំនួន៣២ ក្បាលបានញាស់ ហើយរៀងរាល់សប្តាហ៍តែងមានកូនមាន់សំបុកថ្មីញាស់ជាប្រចាំ ខណៈដែលមេមាន់ពេញវ័យកាន់តែច្រើន។**

នៅឆ្នាំ២០១៦ លោក ចំណាក់ ត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្តល់ថវិកាចំនួន ២៥០ដុល្លារ ដើម្បីទិញមេមាន់ និងមាន់ឈ្មោលមួយចំនួនដើម្បីចាប់ផ្តើមអាជីវកម្មចិញ្ចឹមសត្វលក្ខណៈគ្រួសារ ព្រមទាំងឧបករណ៍ភ្ញាស់មួយឈុតដើម្បីពន្លឿនការភ្ញាស់កូនមាន់ និងការរៀបចំបង្កើតសំបុកដើម្បីការពារមាន់ទាំងនេះ។ នេះជាផ្នែកមួយនៃគំនិតផ្តួចផ្តើមរបស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាលរបស់កម្ពុជា (DAHP) ដើម្បីពង្រឹង និងលើកកម្ពស់ការផ្សព្វផ្សាយវិធីចិញ្ចឹមសត្វនៅតាមតំបន់ជនបទ។

លោក ចំណាក់ ពន្យល់ដូច្នេះថា “ដំបូងឡើយ ខ្ញុំគ្រាន់តែព្យាបាលសត្វក្នុងនាមជាបុគ្គលិកបសុព្យាបាលតាមភូមិប៉ុណ្ណោះ។ ក្រោយមក ទើបខ្ញុំចាប់ផ្តើមចិញ្ចឹមជ្រូក ប៉ុន្តែវាមិនចំណេញទេ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំក៏នៅតែមិនឈប់ចិញ្ចឹមសត្វដែរ។ ខ្ញុំជាបុគ្គលិកបសុព្យាបាល ដូច្នេះខ្ញុំគួរតែអាចចិញ្ចឹមសត្វបាន ពីព្រោះខ្ញុំដឹងពីបច្ចេកទេសចិញ្ចឹម និងថែទាំសត្វឲ្យមានសុខភាពល្អ”។

លោក ចំណាក់ និយាយបន្ថែមទៀតថា “នៅពេលដែលមន្ត្រីកសិកម្មឃុំប្រាប់ពីគម្រោងដែលជាជំនួយឥតសំណងរបស់សហភាពអឺរ៉ុបសម្រាប់ចិញ្ចឹមគោក្របី និងមាន់ទា និងបានសួរថា តើខ្ញុំចាប់អារម្មណ៍ក្នុងការចិញ្ចឹមមាន់ដែរឬទេ ខ្ញុំបានឆ្លើយយ៉ាងលឿនថាខ្ញុំចង់សាកល្បងចិញ្ចឹមមាន់”។

លោក ចំណាក់ បន្តថា “ប្រសិនបើយើងទុកឲ្យមាន់ក្រាបញាស់តាមធម្មតា គឺខាតប្រហែល ១០%។ ប៉ុន្តែ បើយើងប្រើឧបករណ៍សំបុកភ្ញាស់វានឹងជួយឲ្យញាស់បានល្អ”។

បច្ចុប្បន្នបច្ចេកទេសចិញ្ចឹមតាមបែបប្រពៃណីដែលហួសសម័យកំពុងត្រូវបានជំនួសដោយបច្ចេកទេសថ្មីៗហើយកសិករកំពុងទទួលផលប្រយោជន៍ពីបច្ចេកទេសថ្មីៗទាំងនោះ។

លោក ចំណាក់ ក៏បានចូលរួមផងដែរនៅក្នុងសកម្មភាពបង្ហាញណែនាំដល់ប្រជាជនដទៃទៀត នៅក្នុងភូមិរបស់គាត់អំពីរបៀបចាក់វ៉ាក់សាំងសត្វដើម្បីបង្ការជំងឺ។ ចំពោះមាន់ លោកបានបង្រៀនអ្នកចិញ្ចឹមមាន់អំពីរបៀបលាយថ្នាំអង់ទីប៊ីយ៉ូទិច ឬវីតាមីន ដោយអាស្រ័យលើជំងឺសត្វ ចូលទៅក្នុងចំណីសត្វដើម្បីធានាប្រសិទ្ធភាពក្នុងការចិញ្ចឹម។

*“ដោយអនុវត្តបច្ចេកទេសថ្មីទាំងនេះសម្រាប់ការជ្រើសរើសពូជសត្វ និងការផ្តល់វ៉ាក់សាំងបង្ការជំងឺ ជាដើម យើងអាចរកប្រាក់ចំណេញបានច្រើនជាងមុន ពោលគឺប្រហែល ៧០ ទៅ ៨០% ប្រសើរជាងការប្រើបច្ចេកទេសចិញ្ចឹមតាមរបៀបចាស់។”*

**លោក ចំណាក់** កសិករ

លោក ចំណាក់ ចូលចិត្តផ្សព្វផ្សាយអំពីមុខរបរចិញ្ចឹមសត្វរបស់គាត់ ហើយចង់ឃើញកសិករច្រើនថែមទៀតនៅទូទាំងស្រុកនាំគ្នាចិញ្ចឹមសត្វដូចគាត់។

លោក ចំណាក់ និយាយថា “ខ្ញុំសូមផ្តាំផ្ញើចំពោះប្រជាជនផ្សេងទៀតថាតម្រូវការមាន់ចិញ្ចឹមក្នុងស្រុកគឺមានតម្រូវការខ្ពស់។ ដូច្នេះ ខ្ញុំសូមណែនាំកសិករយើងឲ្យនាំគ្នាអនុវត្តតាមស្តង់ដារបច្ចេកទេស ដែលណែនាំដោយអ្នកជំនាញ ហើយបើយើងធ្វើតាមស្តង់ដារបច្ចេកទេស នៅក្នុងការចិញ្ចឹមសត្វនោះយើងនឹងក្លាយជាអ្នកចិញ្ចឹមមាន់ដែលជោគជ័យ”។



*លោកចំណាក់ នៅក្នុងកសិដ្ឋានរបស់គាត់*

*សហភាពអឺរ៉ុប ផ្តល់ការគាំទ្រដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅក្នុងកិច្ចប្រឹងប្រែងដើម្បីពង្រឹងវិស័យកសិកម្មនៅកម្ពុជា ដោយផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងនោះរួមទាំងតាមរយៈ ស្ថាប័នមិនមែនរដ្ឋាភិបាលផងដែរ។ ការគាំទ្ររបស់សហភាពអឺរ៉ុប សំដៅជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងវិស័យកសិកម្ម ដូចជាការផ្សព្វផ្សាយ និងលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ព្រមទាំងការកែលម្អផលិតភាព ការធ្វើទំនើបកម្ម និងអាជីវកម្មផលិតផលកសិកម្ម។ ការវិនិយោគរបស់សហភាពអឺរ៉ុប ទៅលើហេដ្ឋារចនាសម្ព័ន្ធជនបទ បានផ្តោតសំខាន់លើការកែលម្អជីវភាពរស់នៅរបស់គ្រួសារដែលក្រីក្រនិងងាយរងគ្រោះ។*